ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

**មតិសំណេះសំណាល**

**លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា សាលាបឋមសិក្សាញ្ញៅ**
**ស្ថិតក្នុងឃុំញ្ញៅ ស្រុកសន្ទុក ខេត្តកំពង់ធំ**

ថ្ងៃព្រហស្បតិ៍ ៣កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦

សូមគោរព

- **លោក ព្រឹម រដ្ឋា អភិបាលរង នៃគណៈអភិបាលខេត្តកំពង់ធំ**
- **គណៈអធិបតី**
- **លោកនាយក លោកគ្រូ-អ្នកគ្រូ**
- **អ៊ំ ៗ មីង ដែលជាអាណាព្យាបាលសិស្ស និង ក្មួយៗ សិស្សានុសិស្សទាំងអស់ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយជាអនេក ដែលបានចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា ១ខ្នង មាន ៥បន្ទប់នៅសាលាបឋមសិក្សាញ្ញៅ ដ៏ស្រស់ត្រកាល និងការជួសជុលកែលម្អអគារសិក្សា ៣ខ្នង មាន១៣បន្ទប់ ជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋ នៅឃុំញ្ញៅ ស្រុកសន្ទុក ខេត្តកំពង់ធំ នាពេលនេះ។

ខ្ញុំសូមអរគុណ លោក វណ្ណៈ សោភានិត ដែលបានធ្វើរបាយការណ៍យ៉ាងក្បោះក្បាយ។ តាមរយៈរបាយការណ៍នេះ យើងឃើញថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងអាណត្តិកន្លងទៅ និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងអាណត្តិទី៧នេះ ការសិក្សាអប់រំត្រូវបានចាត់ទុកជាអាទិភាពមួយដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានស្តារ និងពង្រឹងវិស័យអប់រំជាបន្តបន្ទាប់ តាមរយៈការពង្រឹងទាំងគុណភាពសិក្សា និងការកសាងអគារសិក្សានៅទូទាំងប្រទេស។ ដោយឡែក នៅខេត្តកំពង់ធំ **ឯកឧត្តម ជា ចាន់តូ** អគ្គទេសាភិបាលកិត្តិយស



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

នៃធនាគារជាតិនៃកម្ពុជា និងជាអតីតតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ តែងតែបានខិតខំប្រឹងប្រែង អស់ពីកម្លាំងកាយចិត្តកសាងសមិទ្ធផលជាច្រើននៅក្នុងខេត្តកំពង់ធំ ជាពិសេសបានបន្សល់ទុក នៅអគារសិក្សាជាច្រើនទាំងបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលបានចូលរួមឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការសាងសង់ និងជួសជុល អគារសិក្សានេះឡើង ព្រមទាំងសូមថ្លែងអំណរគុណចំពោះអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ មន្ទីរអប់រំ យុវជន និងកីឡា លោកនាយក លោកគ្រូ-អ្នកគ្រូ និងដៃគូអភិវឌ្ឍនានា ដែលបានផ្តល់កិច្ច សហប្រតិបត្តិការល្អ និងរួមសាមគ្គីគ្នាកសាងអគារសិក្សាថ្មីនេះឡើងសម្រាប់បម្រើវិស័យអប់រំ និង សម្រួលដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់គ្នា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗទាំងអស់ ជាទីមេត្រី!**

រាជរដ្ឋាភិបាលកម្ពុជាថ្មី ក្រោមការដឹកនាំរបស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** បាននិងកំពុងធ្វើ ដំណើរទៅមុខយ៉ាងស្វាហាប់ និងបន្តយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យសំខាន់ៗនានាក្នុង ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការអភិវឌ្ឍមូលធនមនុស្សជា អាទិភាពនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ សម្រាប់ការអនុវត្តនៅគ្រប់ដំណាក់កាល ដែលសំដៅដល់ ការអប់រំឱ្យមានចំណេះដឹងទូលំទូលាយ ជំនាញពិតប្រាកដ ព្រមទាំងសីលធម៌ គុណធម៌ និង មនសិការស្នេហាជាតិ ជាពិសេសការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ជាក់ស្តែង **សម្តេចធិបតី នាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍គន្លឹះ ៤ចំណុច សំដៅលើកកម្ពស់ គុណភាពអប់រំ ដោយផ្តោតសំខាន់លើការពង្រឹងគុណភាពសាលារៀនរដ្ឋ ដែលរួមមាន៖ ទី១. ការ ពង្រឹងអភិបាលកិច្ច ទី២. ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សានិងសកម្មភាពក្រៅម៉ោង សិក្សាឱ្យស្របទៅតាមតម្រូវការ ក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់ សិស្ស ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស និង ទី៤. ការជំរុញ និងលើកទឹកចិត្តការ ចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក "ភាពជា ដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ"។

ជាក់ស្តែង សាលាបឋមសិក្សាញ្ញៅ គឺជាថ្នាលសិក្សាមូលដ្ឋានមួយដ៏សំខាន់ ដែលបានចូលរួម ចំណែកអភិវឌ្ឍធនធានមនុស្សកម្ពុជា តាមរយៈការពង្រឹងការបណ្តុះបណ្តាលដល់ក្មួយៗសិស្សានុសិស្ស ដែលជាទំពាំងស្នងឫស្សីជំនាន់ក្រោយប្រកបដោយគុណភាព។ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ ពិតជាមានចិត្តសប្បាយរីករាយដែលបានចូលរួម វិភាគទាន ក្នុងដំណើរការពង្រឹងវិស័យអប់រំកន្លងមក។ ជាក់ស្តែង យើងបានរៀបចំការបង្រៀនត្រៀម បំប៉នសម្រាប់សិស្សប្រឡងមធ្យមសិក្សាទុតិយភូមិ បានជួយឧបត្ថម្ភថវិកាដល់សិស្សក្រីក្រក្នុងស្រុក

សន្ទុកជារៀងរាល់ខែ ដើម្បីបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ បានឧបត្ថម្ភអាហារូបត្ថម្ភដូចជាពងមាន់ និងទឹកដោះគោដល់សិស្សានុសិស្សកម្រិតមត្តេយ្យសិក្សានៅទូទាំងស្រុកសន្ទុក ជារៀងរាល់ថ្ងៃសិក្សា និងបានកសាងសមិទ្ធផលនានានៅតាមសាលា។ នាពេលនេះ ក្រៅពីការសាងសង់អគារសិក្សាថ្មីចំនួន ១ខ្នង មាន ៥បន្ទប់ យើងក៏បានជួសជុលអគារសិក្សាចំនួន ៣ខ្នង ស្មើនឹង ១៣បន្ទប់ ដែលមានសភាពទ្រុឌទ្រោម និងអាចបង្កហានិភ័យនានាដល់សិស្សានុសិស្សដែលកំពុងសិក្សាផងដែរ។ តាមរយៈការរាយការណ៍ពីស្ថានភាពអគារ នាពេលបច្ចុប្បន្នដែលខ្ញុំទទួលបាន ការកែលម្អទាំងនេះបានអនុញ្ញាតឱ្យក្មួយៗបានចូលរៀនទាន់ពេលវេលា និងមិនខ្វះខាតបន្ទប់សិក្សាទៀតទេ ជាពិសេសក្មួយៗអាចផ្តោតលើការសិក្សាបានកាន់តែល្អថែមទៀតជាមួយនឹងបរិក្ខារសិក្សាថ្មីៗ ប្រកបដោយសុវត្ថិភាព។ ទន្ទឹមនឹងនេះ ក្មួយៗត្រូវយកចិត្តទុកដាក់ខិតខំរៀនសូត្រឱ្យបានខ្លាំងក្លា ដូចប្រសាសន៍សម្តេចធិបតីនាយករដ្ឋមន្ត្រី ដែលតែងតែលើកឡើងថា "រៀនឱ្យចេះ រៀនឱ្យមានជំនាញ និងរៀនឱ្យមានការងារធ្វើ"។ ដើម្បីរៀនឱ្យចេះ មីងសូមលើកយកនូវអង្គ៤ (សុ ចិ ពុ លិ ឬ ស្តាប់ គិត សួរ កត់ត្រា)។ ក្មួយត្រូវត្រងត្រាប់ស្តាប់លោកគ្រូ-អ្នកគ្រូបង្ហាត់បង្រៀន ហើយគិតសួរខ្លួនឯងសិន តើយល់មេរៀនឬទេ? ប្រសិនមិនយល់ត្រូវសួរលោកគ្រូ អ្នកគ្រូនូវចំនុចដែលក្មួយៗមិនយល់ ហើយដើម្បីចងចាំក្មួយៗត្រូវកត់ត្រាទុកក្នុងសៀវភៅងាយស្រួលរំលឹកនៅពេលក្រោយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗទាំងអស់ ជាទីមេត្រី!**

ការសិក្សាក្នុងស្ថានភាពល្អប្រសើរនេះ មានសារៈសំខាន់ណាស់ ដើម្បីទាក់ទាញឱ្យក្មួយៗចង់បន្តការសិក្សាទៅមុខឱ្យបានវែងឆ្ងាយ។ ហើយខ្ញុំបានផ្តាំសហការីរបស់ខ្ញុំហើយថា យើងត្រូវក្តាប់ឱ្យជាប់សុខទុក្ខរបស់ប្រជាជន មិនមែនត្រឹមតែចុះមកជួយមួយភ្លែតៗនោះទេ ជាពិសេសចំពោះក្មួយៗដែលស្ថិតក្នុងគ្រួសារក្រីក្រ ដែលកន្លងមកអាចប្រឈមនឹងហានិភ័យបោះបង់ចោលការសិក្សា។

ទន្ទឹមនេះ ខ្ញុំក៏សូមជម្រាបជូនមាតាបិតា និងអាណាព្យាបាលសិស្សផងដែរថា ការបញ្ជូនកូនមករៀន មិនត្រឹមតែជាកាតព្វកិច្ចរបស់មាតាបិតាគ្រប់រូបនោះទេ តែក៏ដូចជាការសន្សំប្រាក់ឱ្យកូន និងជួយស្រោចស្រង់ជីវភាពឱ្យរួចផុតពីភាពក្រីក្រផងដែរ ដូចពាក្យស្លោកបរទេសមួយបានពោលថា៖ **"ការសិក្សាគឺជាស្ពានឆ្ពោះទៅអនាគត ចង់មានថ្ងៃស្អែកទាល់តែរៀបចំពីថ្ងៃនេះ"**

លើសពីនេះ ការបញ្ជូនកូនមករៀន ក៏ជាការរួមចំណែកកសាងនិងអភិវឌ្ឍសង្គមជាតិយើងសម្រាប់រយៈពេលវែង ដោយសារក្មួយៗដែលកំពុងសិក្សានាពេលនេះ នឹងក្លាយជាសសរទ្រូងដ៏រឹងមាំប្រកបដោយគុណភាពនៅក្នុងវិស័យនានា ហើយក្មួយៗក៏អាចក្លាយជាថ្នាក់ដឹកនាំ នាពេលអនាគតទៀតផង។ ដូច្នេះ ស្របនឹងអនុសាសន៍របស់ **សម្តេចធិបតី** ក្នុងន័យជំរុញ "ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ" ខ្ញុំសូមលើកទឹកចិត្តឱ្យអ៊ំ ពូ មីង បងប្អូន ជាអាណាព្យាបាលសូមបញ្ជូនកូនមកសាលា ជួយលើកទឹកចិត្តកូន និងបង្កលក្ខណៈងាយស្រួលឱ្យកូនៗបានបន្តការសិក្សា ទាំង

កូនប្រុស និងកូនស្រី។ ជាពិសេស ការបញ្ជូនកុមារីមកសាលារៀន ដើម្បីទទួលបានការសិក្សាអប់រំឱ្យបានពេញលេញ ពិតជាមានសារៈសំខាន់ ដោយសារស្ត្រីដើរតួនាទីក្នុងការអភិវឌ្ឍសង្គមខ្មែរយើង ក៏ដូចជាលើកមុខមាត់កម្ពុជាលើឆាកអន្តរជាតិ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗទាំងអស់ ជាទីមេត្រី!**

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រង ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលបានចូលរួមឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការសាងសង់ និងជួសជុលអគារសិក្សានេះឡើង និងសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ មាតាបិតា-អាណាព្យាបាល ប្រជាពលរដ្ឋក្នុងឃុំញ្ញៅ និងក្មួយៗទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធអគារសិក្សា ក្នុងសាលាបឋមសិក្សាញ្ញៅ នាពេលនេះ និងសូមអរគុណដល់ក្រុមការងារធនាគារជាតិនៃកម្ពុជា អាជ្ញាធរមូលដ្ឋាន និងគណៈគ្រប់គ្រងសាលា ដែលបានចូលរួមសហការរៀបចំកម្មវិធីនេះឡើង។ ខ្ញុំក៏សូមអំពាវនាវឱ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អាជ្ញាធរមានសមត្ថកិច្ច មាតាបិតា និងអាណាព្យាបាលសិស្សទាំងអស់ សូមមេត្តាជួយថែរក្សាអគារសិក្សានេះ ឱ្យបានគង់វង្សជាប្រយោជន៍ ដើម្បីប្រើប្រាស់សមិទ្ធផលទាំងនេះឱ្យបានយូរអង្វែងសម្រាប់កូនចៅជំនាន់ក្រោយរបស់យើងតរៀងទៅ។

ទន្ទឹមនេះ បើទោះបីជាសាលាបឋមសិក្សាញ្ញៅពុំទទួលបានជ័យលាភីសាលារៀនគំរូ ឆ្នាំ ២០២៤-២០២៥ ក៏ដោយ ខ្ញុំសូមលើកទឹកចិត្តដល់លោកនាយក លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលា មេត្តាខិតខំប្រឹងប្រែងជាងមុនបន្ថែមទៀត ដើម្បីឆ្នាំក្រោយៗ សាលាបឋមសិក្សាញ្ញៅនឹងក្លាយជាសាលារៀនគំរូមួយក្នុងចំណោមសាលាគំរូដទៃទៀតដែលទទួលបានជ័យលាភី ដើម្បីលើកកិត្តិយសដល់អ្នកស្រុកសន្ទុក ខេត្តកំពង់ធំយើងនេះ។ ការទទួលបានជ័យលាភីមិនមែនសំដៅដល់ការទទួលបានប្រាក់រង្វាន់នោះទេ ប៉ុន្តែជាការប្តេជ្ញាចិត្តលើកកម្ពស់ និងពង្រឹងគុណភាពវិស័យអប់រំដល់អ្នកស្រុកសន្ទុកយើងនេះ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក នាយក លោកគ្រូ អ្នកគ្រូ អ៊ំ ពូ មីង និងក្មួយៗទាំងអស់ សូមសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សា នៅសាលាបឋមសិក្សាញ្ញៅ ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**